**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ ..១៨....អនក្រ-បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

**មាត្រាមួយ.-**

មាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានធ្វើការកែសម្រួល ដូចតទៅ÷

**មាត្រា៤៤ ថ្មី.-**

អគ្គនាយកដ្ឋានរតនាគារជាតិ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្ម ដូចតទៅ÷

- ជាបេឡាករនិងជាគណនេយ្យករសាធារណៈរបស់រាជរដ្ឋាភិបាល
- គ្រប់គ្រងប្រាក់កាសរបស់រដ្ឋនិងគណនីពិសេសនៃរតនាគារ
- រៀបចំគោលការណ៍និងបទបញ្ញាគណនេយ្យសាធារណៈ
- កាន់កាប់និងតាមដានការអនុវត្តគណនេយ្យទូទៅនិងមជ្ឈការគណនី
- ជានាតុល្យភាពទូទៅនៃគណនី
- ធ្វើទំនាក់ទំនងជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាប្រចាំឆ្នាំ។

**មាត្រា៤៥ ថ្មី.-**

អគ្គនាយកដ្ឋានរតនាគារជាតិ មានភារកិច្ច ដូចតទៅ÷

- គ្រប់គ្រងសាច់ប្រាក់ថ្នាក់កណ្តាល ថ្នាក់មូលដ្ឋាន និងថវិកាស្វយ័ត
- គ្រប់គ្រងគណនីរបស់ក្រសួង ស្ថាប័នថ្នាក់កណ្តាល ថ្នាក់មូលដ្ឋាន គណនីប្រាក់បញ្ញើឯកជន គណនីក្រៅថវិកា និងគណនីពិសេសរបស់រតនាគារ
- គ្រប់គ្រងប្រាក់កាសរបស់រដ្ឋ មូលបត្ររដ្ឋ និងសញ្ញាបណ្ណរដ្ឋ
- ធ្វើតុល្យភាពសាច់ប្រាក់ និងគ្រប់គ្រងចំណូល-ចំណាយថវិកាជាតិ
- កាន់កាប់ និងតាមដានការអនុវត្តគណនេយ្យទូទៅ និងមជ្ឈការគណនី
- រៀបចំគោលការណ៍ និងបទបញ្ញត្តិគណនេយ្យសាធារណៈ
- ជានាតុល្យភាពទូទៅនៃគណនី
- ផ្តល់សេវាដល់គ្រប់ក្រសួង-ស្ថាប័នថ្នាក់កណ្តាលនិងរដ្ឋបាលថ្នាក់មូលដ្ឋាន លើការទូទាត់ ការចំណាយផ្សេងៗ ការបើកបៀវត្ស និងការប្រមូលចំណូល ស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ធ្វើទំនាក់ទំនងជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាប្រចាំឆ្នាំ។

**មាត្រា៤៦ ថ្មី.-**

អគ្គនាយកដ្ឋានរតនាគារជាតិ មានរចនាសម្ព័ន្ធនៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ដូចខាងក្រោម÷

ក-ថ្នាក់កណ្តាល

- នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក
- នាយកដ្ឋានចំណូលនិងចំណាយថវិកា
- នាយកដ្ឋានគណនេយ្យ
- នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ
- នាយកដ្ឋានព័ត៌មានវិទ្យា
- អធិការកិច្ចរតនាគារ ថ្នាក់ស្មើនាយកដ្ឋាន
- នាយកដ្ឋានគ្រប់គ្រងសាច់ប្រាក់ និងវិភាគការអនុវត្តថវិកា។

ខ-ថ្នាក់មូលដ្ឋាន

នៅរាជធានី ខេត្ត មានរតនាគាររាជធានី ខេត្ត ដែលដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាននៅថ្នាក់កណ្តាល អមដោយអនុប្រធានមួយចំនួនជាជំនួយការ មានឋានៈស្មើប្រធានការិយាល័យនៅថ្នាក់កណ្តាល។

**មាត្រា៤៧ ថ្មី.-**

នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងាររដ្ឋបាលនិងបុគ្គលិក។

នាយកដ្ឋានចំណូលនិងចំណាយថវិកា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារចំណូលនិងចំណាយថវិកា។

នាយកដ្ឋានគណនេយ្យ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគណនេយ្យ។

នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ។

នាយកដ្ឋានព័ត៌មានវិទ្យា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារព័ត៌មានវិទ្យា។

អធិការកិច្ចរតនាគារ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារអធិការកិច្ចរតនាគារ។

នាយកដ្ឋានគ្រប់គ្រងសាច់ប្រាក់ និងវិភាគការអនុវត្តថវិកា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគ្រប់គ្រងសាច់ប្រាក់ និងវិភាគការអនុវត្តថវិកា។

**មាត្រាពីរ.-**

អង្គការលេខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួលដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ..៦៩...អនក្រ.បក
ចុះថ្ងៃទី..១៣...ខែ..មីនា......ឆ្នាំ២០១៥
ឧបសម្ព័ន្ធថ្មី នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក
ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣

# អង្គការលេខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- រដ្ឋមន្ត្រី
  - រដ្ឋលេខាធិការ
    - អនុរដ្ឋលេខាធិការ
  - ទីប្រឹក្សា
  - ខុទ្ទកាល័យ
  - អគ្គលេខាធិការដ្ឋាន
    - នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
    - នាយកដ្ឋានបុគ្គលិក
    - នាយកដ្ឋាននីតិកម្ម
    - នាយកដ្ឋានព័ត៌មានវិទ្យា
    - នាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍
    - វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
    - មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
  - អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ
    - នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ
    - នាយកដ្ឋានស្ថិតិ
    - នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាន
  - អគ្គនាយកដ្ឋានថវិកា
    - នាយកដ្ឋានកិច្ចការទូទៅ
    - នាយកដ្ឋានថវិកាវិនិយោគ
    - នាយកដ្ឋានហិរញ្ញកិច្ច
    - នាយកដ្ឋានវិនិយោគ
    - នាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល
  - អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
    - នាយកដ្ឋានគ្រប់គ្រងរដ្ឋបាល និងបច្ចេកទេស
    - នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលរាជធានី ខេត្ត
    - នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក
    - នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់
  - អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
    - នាយកដ្ឋានរដ្ឋបាលបុគ្គលិក និងផែនការ
    - នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ
    - នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា
    - នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ
    - នាយកដ្ឋានត្រួតពិនិត្យ និងដោះស្រាយវិវាទ
  - អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
    - នាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង
    - នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ
    - នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ
    - នាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស
    - នាយកដ្ឋានរដ្ឋាករ
    - នាយកដ្ឋានរបបគយ
    - នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ
    - លេខាធិការដ្ឋាន
    - ថ្នាក់មូលដ្ឋាន
  - អគ្គនាយកដ្ឋានពន្ធដារ
    - នាយកដ្ឋានបុគ្គលិក និងរដ្ឋបាលហិរញ្ញវត្ថុ
    - នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ
    - នាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ
    - នាយកដ្ឋានត្រួតពិនិត្យ
    - នាយកដ្ឋានព័ត៌មានវិទ្យា
    - នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
    - នាយកដ្ឋានសវនកម្មសហគ្រាស
    - ថ្នាក់មូលដ្ឋាន
  - អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ
    - នាយកដ្ឋានសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
    - នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ
    - នាយកដ្ឋានចំណូលសាធារណៈ
    - នាយកដ្ឋានសហគ្រាសសាធារណៈ
  - អគ្គនាយកដ្ឋានរតនាគារជាតិ
    - នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក
    - នាយកដ្ឋានចំណូល និងចំណាយថវិកា
    - នាយកដ្ឋានគណនេយ្យ
    - នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាន និងសារពើស្ថិតិ
    - នាយកដ្ឋានព័ត៌មានវិទ្យា
    - អធិការកិច្ចរតនាគារ
    - នាយកដ្ឋានគ្រប់គ្រងសាច់ប្រាក់និងវិភាគការអនុវត្តថវិកា
    - ថ្នាក់មូលដ្ឋាន
  - អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
    - នាយកដ្ឋានធានារ៉ាប់រង និងសោធន
    - នាយកដ្ឋានទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុ
    - នាយកដ្ឋានគ្រប់គ្រងអាជីវកម្មភ្នាល់ និងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
    - នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន
  - អគ្គាធិការដ្ឋាន
    - នាយកដ្ឋានរដ្ឋបាល ផែនការ និងសិក្សាស្រាវជ្រាវបណ្តឹង
    - នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ជាតិ
    - នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
  - អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង
    - នាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់កណ្តាល
    - នាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់មូលដ្ឋាន